

# ទន្សាយ និង អណ្តើក (ជាថ្មី!)

Venkatramana Gowda

Padmanabh

Let's Read
The Asia Foundation



តើនៅចាំពីការរត់ប្រណាំងដ៏អស្ចារ្យរវាងទន្សាយ និងអណ្ដើក ឬទេ? ជាយូរមកហើយ សត្វទាំងឡាយក្នុងអាណាចក្រសត្វទាំងមូល មិននិយាយអ្វីក្រៅតែអំពីការរត់ប្រណាំង និងគូប្រកួតទាំងពីរនេះឡើយ។



យើងដឹងហើយថាទន្សាយចាញ់ដោយសារវាខ្ជិល និងមានអំណួតខ្លាំងពេក។ យើងដឹងហើយថាអណ្តើកឈ្នះដោយសារវាព្យាយាមមិនខ្ជិល ទោះបីជាវាយឺតក៏ដោយ។ សត្វព្រៃទាំងអស់ក៏ដឹងរឿងនេះ ហើយតែងគោរពសត្វទាំងពីរស្មើគ្នារហូតមក។



ទោះបីជាគូប្រជែងគ្នាក្តី ក៏ពួកគេនៅតែជាមិត្តនឹងគ្នា។ អណ្តើកមិនដែលមានអំណួតព្រោះតែខ្លួនឈ្នះនោះឡើយ។ ឯទន្សាយវិញក៏ពុំដែលគុំគួនលើអណ្តើកដែរ ព្រោះវាដឹងខ្លួនថាចាញ់ដោយយុត្តិធម៌។



ច្រើនខែកន្លងផុតទៅ។ ស្ដេចសត្វព្រៃដែលទន្សាយ និងអណ្ដើក រស់នៅ មានកិច្ចការសំខាន់ត្រូវពិភាក្សាជាមួយស្ដេចសត្វព្រៃ ដែលនៅជិតខាង។ ប៉ុន្តែស្ដេចសត្វនេះ មិនអាចចេញពីព្រៃរបស់ខ្លួនបាននៅពេលនេះឡើយ។ ព្រះអង្គក៏សម្រេចបញ្ជូនទន្សាយ និងអណ្ដើកឲ្យទៅជំនួសក្នុងនាមព្រះរាជតំណាង។



ស្តេចសត្វព្រៃក៏កោះហៅទន្សាយ និងអណ្តើកមកជួប។ ស្តេចសត្វក៏ចេញព្រះរាជបញ្ជាថា៖ ”ក្នុងចំណោមពួកឯង ត្រូវមានម្នាក់ចេញទៅជួបស្តេចសត្វព្រៃជិតខាងនេះ។”



«យើងមានកិច្ចការសំខាន់ៗចង់ឲ្យឯងពិភាក្សាជាមួយស្ដេចសត្វព្រៃនៅទីនោះជំនួសយើង។ ពេលត្រឡប់មកវិញ ពួកឯងត្រូវនាំយកគំនិតរបស់ទ្រង់មកប្រាប់យើងវិញឬទេ?»

ស្ដេចសត្វបានបញ្ជាក់ទៀតថា៖ «ត្រូវចាំថាពួកឯងមានពេលតែមួយថ្ងៃប៉ុណ្ណោះដើម្បីធ្វើកិច្ចការនេះ។ ឥឡូវពួកឯងអាចទៅបានហើយ ប៉ុន្តែត្រូវប្រយ័ត្នផង។»



តាមផ្លូវទៅកាន់អាណាចក្រព្រៃមួយទៀតនោះ គឺពិបាកធ្វើដំណើរណាស់។ ផ្លូវនោះសម្បូរទៅដោយថ្មរដិបរដុប និងដើមបន្លាយក្សធំៗទៀតផង។ បន្តពីនោះទៅ នៅមានទន្លេពីរដែលត្រូវឆ្លងទៀតផង។



គិតមួយស្របក់ ទន្សាយ និងអណ្ដើក ដឹងថាពួកគេមិនអាច បំពេញភារកិច្ចនេះ តែម្នាក់ឯងបានឡើយ។ ពួកគេក៏សម្រេចចិត្ត ធ្វើដំណើររួមគ្នា។ សត្វទាំងពីរក៏គិតរៀបចំ ផែនការ។ បើតាមផ្លូវ ដែលមានដើមបន្លាយក្ស ទន្សាយត្រូវដឹកអណ្ដើកពីក្រោយខ្នង។ ឯពេលឆ្លងទន្លេ អណ្ដើកក៏ត្រូវដឹកទន្សាយពីលើខ្នងវិញម្ដង។



នៅថ្ងៃបន្ទាប់ ពួកគេក៏យកព្រះរាជសារពីស្តេចរបស់ខ្លួន ហើយក៏ចេញដំណើរ។ ទន្សាយធ្វើដំណើរតែបន្តិចក៏ឆ្លងផុតផ្លូវដែលមានដើមបន្លាយក្ស។ នេះក៏ព្រោះតែវាលោតម្តងៗបានឆ្ងាយ ហើយមានស្នូកអណ្តើកដ៏រឹងលើខ្នងវាការពារបន្លា។ ឯអណ្តើកវិញត្រូវប្រឹងទប់ ក្រែងធ្លាក់ពីលើខ្នងទន្សាយ។



នៅពេលដល់ទន្លេ ពួកគេក៏ប្តូរវេនគ្នាតាមផែនការ។ ទន្សាយក៏លោតទំលើខ្នងអណ្តើកម្តង។ អណ្តើកក៏ហែលឆ្លងទន្លេយ៉ាងលឿនដោយស្ទាត់ជំនាញ។ ឆ្លងទន្លេផុតមិនយូរប៉ុន្មាន ពួកគេក៏ទៅដល់អាណាចក្រនោះ។



បន្ទាប់មកពួកគេក៏ពិភាក្សាកិច្ចការជាមួយស្ដេចសត្វព្រៃនៅ
ទីនោះតាមព្រះរាជបណ្ដាំ ស្ដេចរបស់ខ្លួន។ ចប់រួចរាល់ ទន្សាយ
និងអណ្ដើក ក៏ត្រៀមវិលត្រឡប់មកវិញ។



ការដំណើរត្រឡប់មកវិញ កាន់តែរលូនជាងតាមផ្លូវធ្វើដំណើរមក។ កត្តានេះដោយសារដៃគូទាំងពីរដឹងច្បាស់ពីអ្វីដែលខ្លួនត្រូវធ្វើ។ សត្វដែលធ្លាប់តែជាគូបដិបក្ខនឹងគ្នា បានសហការគ្នាយ៉ាងល្អ។ ទីបំផុត ពួកគេក៏អាចត្រឡប់មកជួបស្តេចរបស់ខ្លួនវិញ មុនពេលវេលាកំណត់ពីរបីម៉ោងឯណោះ។





សូមប្រើការស្រមើស្រមៃរបស់ប្អូនៗ ដើម្បីផាត់ពណ៌រូបនេះ
តាមដែលប្អូនចូលចិត្ត។



សូមប្រើការស្រមើស្រមៃរបស់ប្អូនៗ ដើម្បីផាត់ពណ៌រូបនេះ
តាមដែលប្អូនចូលចិត្ត។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Hare & the Tortoise (Again!)*, Author: Venkatramana Gowda. Illustrator: Padmanabh. Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang and Nasema Zeerak